**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្លែងក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍ថ្នាក់ជាតិប្រកបដោយចីរភាពនៅកម្ពុជា

សណ្ឋាគារហ៊ីម៉ាវ៉ារី ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧

- *លោកស្រី Vladanka Andreeva នាយកប្រចាំប្រទេសនៃអង្គការ UNAIDS*
- *លោកស្រី Mindy Duong អ្នកសម្របសម្រួលអន្តរទីភ្នាក់ងារ PEPFAR*
- *លោកស្រី Marta Levitt ទីប្រឹក្សាជាន់ខ្ពស់នៃប្រព័ន្ធពង្រឹងសុខភាព និងមេរោគអេដស៍ ការិយាល័យសុខាភិបាល និងអប់រំ នៃទីភ្នាក់ងារ USAID*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងស្ថាប័នរាជរដ្ឋាភិបាល អង្គទូត ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល*
- *អស់លោក លោកស្រីជាទីប្រឹក្សាបច្ចេកទេស និងអ្នកជំនាញការជាតិ និងអន្តរជាតិ*
- *អ្នកតំណាងប្រជាជនទទួលរងផលប៉ះពាល់គន្លឹះ*
- *អស់លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ជាទីរាប់អាន*

ជាបឋម តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកថ្លែងក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍ថ្នាក់ជាតិប្រកបដោយចីរភាពនៅកម្ពុជា ដ៏មានសារៈសំខាន់នាពេលនេះ។ ជាមួយគ្នានេះ ខ្ញុំក៏សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ដែលអញ្ជើញមកពីវិស័យសុខាភិបាល និង មិនមែនសុខាភិបាល រួមជាមួយអ្នកតំណាងនៃប្រជាជនគន្លឹះ និងជាពិសេសចំពោះការគាំទ្រផ្នែក

បច្ចេកទេស និងហិរញ្ញវត្ថុពី PEPFAR/រដ្ឋាភិបាលសហរដ្ឋអាម៉េរិក និង USAID ក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់នេះ។

នៅក្នុងសិក្ខាសាលានេះ យើងនឹងចែករំលែកទស្សនៈ និងរៀនសូត្រអំពីគ្នាទៅវិញទៅមកអំពីវិធីក្នុងការជួយឱ្យប្រទេសរបស់យើងឆ្លងផុតដំណាក់កាលអន្តរកាល និងត្រៀមខ្លួនបានល្អឆ្ពោះទៅកាន់ ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាព ហើយកាន់តែសំខាន់ជាងនេះទៅទៀតគឺជួយយើងឱ្យសម្រេចបាននូវកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបញ្ចប់នូវការរីករាលដាលជំងឺអេដស៍នៅឆ្នាំ២០២៥ គឺរយៈពេល៥ឆ្នាំមុនផែនការសកលលោក។ យើងនឹងចំណាយពេលពេញមួយថ្ងៃ ដើម្បីជជែកគ្នាអំពីប្រធានបទគន្លឹះដែលជាមូលដ្ឋានគ្រឹះនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដូចខាងក្រោម ៖

១) បច្ចុប្បន្នភាពអំពីស្ថានភាពនៃកម្មវិធីមេរោគអេដស៍/ជំងឺអេដស៍បច្ចុប្បន្ន
២) ការយល់ដឹងច្បាស់អំពីចីរភាព (ទស្សនៈ និងបទពិសោធន៍សកល)
៣) ផែនការអន្តរកាល និងអនុសាសន៍ត្រៀមបម្រុង
៤) តារាង និងបរិធានចីរភាព

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!*

ជាដំបូងនេះ អនុញ្ញាតឱ្យខ្ញុំរំឭកពីសុន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលបានថ្លែងក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ នៅពេលដែលពិភពលោកប្តេជ្ញាធ្វើដំណើរពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ពេលនោះសម្តេចតេជោបានគូសបញ្ជាក់ថា អស់រយៈពេលជាងពីរទសវត្សរ៍ កម្ពុជាបានធ្វើឱ្យមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងការធានាបាននូវសន្តិភាពពេញលេញ ស្ថិរភាពនយោបាយរឹងមាំ និងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខសាធារណៈ ជាមួយនឹងកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ជាមធ្យម ៧,៧% ប្រចាំឆ្នាំ និងថា ប្រទេសកម្ពុជាបានប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៦។ នៅក្នុងពេលមួយនៃជំនួបជាមួយលោក Steve Kraus ប្រធានអង្គការUNAIDS ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក សម្តេចតេជោបានសង្កត់ធ្ងន់ថា ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាគឺ "ធ្វើពីក្បាលដល់ចុងជើង" មានន័យថា ម្នាក់ៗ និងគ្រប់វិស័យបានចូលរួមឆ្លើយតបនឹងមេរោគអអេដស៍ និងជំងឺអេដស៍។

បន្ថែមពីលើនេះ ខ្ញុំសូមឆ្លៀតឱកាសនេះបញ្ជាក់ជូនថា រហូតដល់ដំណាច់ឆ្នាំ២០១៧ (ឬជាងពីរទសវត្សរ៍កន្លងមក) ថវិកាប្រមាណ៨០០លានដុល្លារត្រូវបានធ្វើចលនាក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ការឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជាគឺជា រឿងរ៉ាវនៃជោគជ័យមួយរបស់ពិភពលោកដែលបានបង្វិលត្រឡប់ពីការឆ្លងរីករាលដាល ដែលឥឡូវនេះ ប្រទេសកម្ពុជាជិតនឹងសម្រេចបាននូវការទទួលបានការព្យាបាលមេរោគអេដស៍ជាសកលហើយ។

កម្ពុជាបានឈានមកដល់ចំណុចនេះដោយសារការប្តេជ្ញានយោបាយដ៏មោះមុត ការចូលរួមពីសហគមន៍ និងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុកម្រិតខ្ពស់ អស់រយៈពេលជាងពីរទសវត្សរ៍ ពីដៃគូអភិវឌ្ឍន៍។ ទោះបីយ៉ាងណា កញ្ចប់ថវិកាពីខាងក្រៅក្នុងការឆ្លើយតបនឹងមេរោគអេដស៍កំពុងរួមតូច ហើយមានការព្រួយបារម្ភថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងនៅក្នុងឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបថ្មីនេះ នឹងកាន់តែធ្វើឱ្យយើងមានសិទ្ធិតិចតួចក្នុងការទទួលបានជំនួយអភិវឌ្ឍន៍ផ្លូវការ។

ដោយសារការទទួលស្គាល់បែបនេះហើយ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាប្រើប្រាស់នូវប្រភពធនធានដែលមានឱ្យប្រកបដោយយុទ្ធសាស្ត្រ ក្នុងពេលដែលរៀបចំខ្លួនក្នុងការទទួលយកនូវចំណែកកាន់តែធំឡើងនៃបន្ទុកហិរញ្ញវត្ថុក្នុងការឆ្លើយតប។ កន្លងមកនេះ យុទ្ធសាស្ត្រជាគោលដៅ គំរូសេវាកម្មដែលកាន់តែមានប្រសិទ្ធភាព ការរួមគ្នាធ្វើឱ្យសម្រេចនៅក្នុង និងរវាងសាធារណជន និងប្រព័ន្ធសុខាភិបាលសហគមន៍ បានរួមចំណែកធ្វើឱ្យមានការធ្លាក់ចុះទាំងស្រុងក្នុងការចំណាយលើជំងឺអេដស៍តាំងពីឆ្នាំ២០១០។ ទោះបីយ៉ាងណា នៅក្នុងដំណាក់កាលអន្តរកាលនេះ ការបន្តផ្តល់ថវិកាក្នុងកម្រិតទស្សន៍ទាយបានមួយនឹងត្រូវការចាំបាច់ ដើម្បីធ្វើឱ្យមានចីរភាព និងកសាងបាននូវផលចំណេញផ្នែកសុខាភិបាលដែលត្រូវបានធ្វើឡើងមកដល់សព្វថ្ងៃនេះ។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!*

សូមពិនិត្យមើលនូវការប្តេជ្ញាចិត្ត និងកិច្ចប្រឹងប្រែងនានាដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងដំណាក់កាលអន្តរកាលនេះ ៖

១) យោងតាមរបាយការណ៍វាយតម្លៃការចំណាយលើជំងឺអេដស៍ថ្នាក់ជាតិចុងក្រោយ បានទទួលស្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាបានរួមចំណែកជាថវិកាចំនួន ៨,២លានដុល្លារអាម៉េរិក (ឬ១៨,៥%) នៃការចំណាយលើជំងឺអេដស៍សរុបក្នុងឆ្នាំ២០១៥។

២) ពីក្រុមការងារបច្ចេកទេសរួមរដ្ឋាភិបាល និងម្ចាស់ជំនួយ សូចនាករត្រួតពិនិត្យរួមចុងក្រោយមួយនោះគឺ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាដែលសន្យាថា នឹងបង្កើនថវិការហូតដល់ ១១លានដុល្លារក្នុងឆ្នាំ២០១៧ និង១២លានដុល្លារក្នុងឆ្នាំ២០១៨។

៣) រាជរដ្ឋាភិបាលកម្ពុជាបានរួមចំណែកជាថវិកាចំនួន ៣,៧លានដុល្លារក្នុងការទិញឱសថប្រឆាំងមេរោគអេដស៍ និងឱសថព្យាបាលជំងឺឱកាសនិយម ពីឆ្នាំ២០១៥ ដល់២០១៧ ហើយកម្ពុជានឹងបន្ថែមកញ្ចប់ថវិកានេះរហូតដល់ ៤,៥លានដុល្លារពីឆ្នាំ២០១៨ដល់២០២០ ក្នុងការទិញឱសថទាំងនេះ។

៤) តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាឯកភាពក្នុងការផ្តល់សហហិរញ្ញវត្ថុ ៥,២លានដុល្លារ ដើម្បីទាក់ទាញនូវការគាំទ្រពេញលេញនូវសំណើថវិកា ៤១,៦លានដុល្លារពីមូលនិធិសកល នៅឆ្នាំ២០១៨-២០២០។

៥) បន្ថែមពីលើនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិងកំពុងគាំទ្រឱ្យមានការគាំទ្រពហុវិស័យក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលក្នុងនោះ សមាជិក

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានណែនាំឱ្យរៀបចំកញ្ចប់ថវិកាផ្ទាល់របស់ពួកគេក្នុងផែនការវិនិយោគផ្ទាល់ របស់ពួកគេ នៅក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ ២០១៧ នៅខេត្តកំពង់ធំ។

៦) លើសពីការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុ ការចូលរួមគួរឱ្យកត់សម្គាល់ផ្នែកស្ថាប័នត្រូវបានសង្កេតឃើញតាមរយៈ ការទទួលយកទៅពិចារណានូវ តួនាទីប្រធានគណៈកម្មាធិការសម្របសម្រួល ជំនួយមូលនិធិសកលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការដើរតួនាទីជាអ្នកទទួលជំនួយផ្ទាល់ ស្របពេលដែលក្រសួងសុខាភិបាល ទទួលតួនាទីជាអ្នកសម្របសម្រួល (ជាក្រុមអនុវត្តឈានមុខ) នៃហិរញ្ញប្បទានពីមូលនិធិសកល សម្រាប់ឆ្នាំ២០១៨-២០២០ខាងមុខ។ សំខាន់ជាងនេះទៅទៀត ស្តង់ដារប្រតិបត្តិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងត្រូវបានប្រើប្រាស់ជំនួសស្តង់ដារប្រតិបត្តិការរបស់មូលនិធិសកល។

៧) ដោយមានការគាំទ្រពីក្រសួងផែនការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានប្រឹងប្រែងក្នុងការសម្របសម្រួលឱ្យអ្នកជំងឺអេដស៍ទទួលបាន អត្តសញ្ញាណប័ណ្ណគ្រួសារក្រីក្រ ដែលចាប់ផ្តើមពី ខេត្តចំនួន៨ ក្នុងឆ្នាំ២០១៦។ នេះជាការបើកផ្លូវឆ្ពោះទៅកាន់ការគាំទ្រឱ្យមានការគាំពារសង្គមជាប្រព័ន្ធមួយ (ដែលរួមបញ្ចូលនូវមូលនិធិសមធម៌សុខាភិបាល) ទៅដល់តម្រូវការដ៏ធំធេងនៃគ្រួសារដែលទទួលរងគ្រោះដោយមេរោគអេដស៍ និងប្រជាជនគន្លឹះនៅតាមទីក្រុង។

៨) ដើម្បីគាំទ្រនូវកិច្ចប្រឹងប្រែងក្នុងវិមជ្ឈការ ខ្ញុំសូមជម្រាបជូនថា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍កំពុងធ្វើផែនការរៀបចំស្តង់ដារប្រតិបត្តិការដោយដាក់បញ្ចូលមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/ផែនការវិនិយោគឃុំ។

ខ្ញុំសូមបញ្ជាក់ជូនជាថ្មីថា កិច្ចប្រឹងប្រែងទាំងនេះមានគោលបំណងពង្រឹងសមត្ថភាពរបស់យើងក្នុងការឆ្លើយតប ដោយបង្កើនការធ្វើឱ្យសម្រេចរួមគ្នា និងប្រសិទ្ធផលហិរញ្ញវត្ថុ ដោយមានការគាំទ្រយ៉ាងរឹងមាំពីប្រព័ន្ធរបស់ប្រទេស។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ចេញពីសិក្ខាសាលាពីគ្រោះយោបល់នេះ យើងនឹងបានរៀនសូត្រអំពី បច្ចុប្បន្នភាពនៃស្ថានភាពការឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជា។ យើងនឹងយល់អំពីទស្សនៈនៃចីរភាព និងក្តាប់បាននូវបទពិសោធន៍នានានៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ យើងនឹងផ្តល់ផងដែរនូវធាតុចូលក្នុងការរៀបចំនូវផែនទីបង្ហាញផ្លូវនៃសកម្មភាពអាទិភាព ដើម្បីលើកឡើងនូវហានិភ័យនានាចំពោះចីរភាព ដែលជួយយើងបង្កើតបាននូវផ្លូវធ្វើដំណើរដ៏រលូនមួយនៅក្នុងអន្តរកាលនេះ។

ខ្ញុំសូមអំពាវនាវដល់អ្នកចូលរួមទាំងអស់ឱ្យធ្វើការរួមគ្នា ក្នុងការធ្វើបច្ចុប្បន្នភាពផ្នែកគន្លឹះនៃតារាង និងបរិបានចីរភាព ហើយធ្វើការវិភាគរួមគ្នា ក្នុងពេលដែលសម្លឹងមើលទៅឱកាសក្នុងការយកឈ្នះបញ្ហាប្រឈមនានាដែលកើតមានឡើង។

ជាទីបញ្ចប់នេះ ខ្ញុំសូមជម្រាបជូនអង្គសិក្ខាសាលាថា ខ្ញុំចង់រៀនសូត្រពីវេទិកានេះ។ ជាពិសេសខ្ញុំចង់ដឹងថា តើអ្វីទៅជាសេណារីយ៉ូក្នុងការពិភាក្សារកដំណោះស្រាយក្នុងការកាត់បន្ថយយ៉ាងសន្ធឹកសន្ធាប់នៃការគាំទ្រពីខាងក្រៅក្រោយឆ្នាំ២០២០? ខ្ញុំដឹងថា បច្ចុប្បន្នអ្នកស្ម័គ្រចិត្តថ្នាក់ក្រោមចំនួន ២.០០០នាក់កំពុងស្វែងរកអ្នកជំងឺអេដស៍ ១២.០០០នាក់ដែលបាត់ខ្លួនមិនស្ថិតនៅក្នុងប្រព័ន្ធសុខាភិបាល។ ហើយអ្នកស្ម័គ្រចិត្តទាំងនោះ កំពុងផ្តល់សេវាដល់អ្នកជំងឺអេដស៍ និងប្រជាជនគន្លឹះដែលត្រូវការបំផុត ដែលកំពុងស្ថិតនៅក្នុងប្រព័ន្ធសុខាភិបាល។ តើនឹងមានអ្វីកើតឡើងចំពោះអ្នកស្ម័គ្រចិត្តថ្នាក់ក្រោមទាំងនោះ ប្រសិនបើមិនមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ដល់ពួកគេបន្តទៀត។

ខ្ញុំសូមសម្តែងនូវការអបអរសាទរចំពោះ រដ្ឋាភិបាលសហរដ្ឋអាម៉េរិក/PEPFAR ដែលបានរៀបចំឱ្យមានការផ្តួចផ្តើមនេះ ដើម្បីជួយដល់អ្នកពាក់ព័ន្ធគន្លឹះឱ្យចូលរួមក្នុងកិច្ចសន្ទនាដ៏មានសារៈសំខាន់នេះ។

ខ្ញុំក៏សូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអ្នកចូលរួមទាំងអស់នូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក "សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍ថ្នាក់ជាតិប្រកបដោយចីរភាពនៅកម្ពុជា" ចាប់ពីពេលនេះតទៅ។

*សូមអរគុណ!*